# ច្បាប់

# ស្តីពី

# លក្ខន្តិកៈសមាជិកព្រឹទ្ធសភា

# ច្បាប់

# ស្តីពី

# លក្ខន្តិកៈសមាជិកព្រឹទ្ធសភា

# ជំពូកទី ១
## បទបញ្ញត្តិទូទៅ

**មាត្រា ១.-**

ច្បាប់នេះមានគោលដៅកំណត់នូវអភ័យឯកសិទ្ធិសភា ឋានៈ បុព្វសិទ្ធិ វិសមិតភាព និងល័ក្ខខ័ណ្ឌចាំបាច់នានា ដើម្បីជានាជូនដល់សមាជិកព្រឹទ្ធសភាក្នុងការបំពេញភារកិច្ចស្របតាមរដ្ឋធម្មនុញ្ញ ច្បាប់ និងលិខិតបទដ្ឋាននៃព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា ២.-**

សមាជិកព្រឹទ្ធសភាក្នុងព្រឹទ្ធសភា គឺជាតំណាងរបស់ប្រជាជាតិខ្មែរទាំងមូល ពុំមែនគ្រាន់តែជាតំណាងឱ្យភូមិភាគរបស់ខ្លួននោះទេ ។

**មាត្រា ៣.-**

សមាជិកព្រឹទ្ធសភាមានអាណត្តិ ៦ ឆ្នាំ (ប្រាំមួយឆ្នាំ) ហើយត្រូវផុតកំណត់នៅពេលសមាជិកព្រឹទ្ធសភាថ្មីចូលកាន់តំណែង ។

## ជំពូកទី ២
## អភ័យឯកសិទ្ធិសភា

**មាត្រា ៤.-**

សមាជិកព្រឹទ្ធសភាមានអភ័យឯកសិទ្ធិសភា ។ អភ័យឯកសិទ្ធិសភា ត្រូវបានចែកចេញជាពីរផ្នែក :

-ការធានាក្នុងការបញ្ចេញយោបល់ ឬ ការបញ្ចេញមតិក្នុងការអនុម័តទាំងឡាយរបស់សមាជិកព្រឹទ្ធសភា នៅក្នុងក្របខ័ណ្ឌនៃការបំពេញតួនាទីជាសមាជិកព្រឹទ្ធសភា គឺជាអភ័យឯកសិទ្ធិដាច់ខាត ។

-ការធានាមិនឱ្យមានការចោទប្រកាន់ ការចាប់ខ្លួន ឬ ការឃុំខ្លួនសមាជិកព្រឹទ្ធសភាណាមួយ គឺជាអភ័យឯកសិទ្ធិដោយប្រៀប ។

**មាត្រា ៥.-**

សមាជិកព្រឹទ្ធសភា មិនអាចឆ្លៀតប្រើអភ័យឯកសិទ្ធិសភានេះដោយរំលោភ នាំឱ្យប៉ះពាល់ដល់កិត្តិយសរបស់បុគ្គលដទៃ ដល់ទំនៀមទំលាប់ល្អរបស់សង្គម ដល់សណ្តាប់ធ្នាប់សាធារណៈ និងដល់សន្តិសុខជាតិបានឡើយ ។

**មាត្រា ៦.-**

សមាជិកព្រឹទ្ធសភា ត្រូវគោរពបទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភានៃព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា ៧.-**

សមាជិកព្រឹទ្ធសភាដែលបានប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌនឹងអាចអនុញ្ញាតបើកឱ្យធ្វើការចោទប្រកាន់ ការចាប់ខ្លួន ការឃាត់ខ្លួន ឬ ការឃុំខ្លួនតាមច្បាប់ និងនីតិវិធីបាន លុះត្រាតែមានការលើកអភ័យឯកសិទ្ធិសភាជាមុនសិន ។

**មាត្រា ៨.-**

សេចក្តីស្នើសុំលើកអភ័យឯកសិទ្ធិសភារបស់សមាជិកព្រឹទ្ធសភារូបណាមួយ ត្រូវធ្វើឡើងដោយអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ តាមរយៈរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ដោយមានភ្ជាប់សេចក្តីថ្លែងហេតុមកជាមួយផង ផ្ញើជូនប្រធានព្រឹទ្ធសភា ។

**មាត្រា ៩.-**

ការលើកអភ័យឯកសិទ្ធិសភាក្នុងរយៈពេលសម័យប្រជុំព្រឹទ្ធសភា ត្រូវអនុវត្តតាមនីតិវិធីខាងក្រោមនេះ :

-ព្រឹទ្ធសភាអាចប្រជុំជាសម្ងាត់តាមការស្នើសុំពីប្រធាន ឬ ពីសមាជិកព្រឹទ្ធសភាចំនួនមួយភាគដប់យ៉ាងតិច ពីព្រះមហាក្សត្រ ពីនាយករដ្ឋមន្ត្រី ឬ ពីប្រធានរដ្ឋសភា ។

-កូរ៉ុមប្រជុំលើសពី ពីរភាគបីនៃសមាជិកព្រឹទ្ធសភាទាំងមូល ។

-ការអនុម័តតាមមតិភាគច្រើនពីរភាគបីនៃចំនួនសមាជិកព្រឹទ្ធសភាទាំងមូល ។

**មាត្រា ១០.-**

ការលើកអភ័យឯកសិទ្ធិសភាក្នុងចន្លោះសម័យប្រជុំព្រឹទ្ធសភា គណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភាត្រូវប្រជុំ និងអនុម័តស្របតាមបទបញ្ជាផ្ទៃក្នុងនៃព្រឹទ្ធសភា ។

**មាត្រា ១១.-**

សេចក្ដីសម្រេចរបស់គណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា ត្រូវដាក់ជូនសម័យប្រជុំព្រឹទ្ធសភាខាងមុខ ដើម្បីអនុម័តតាមមតិភាគច្រើនពីរភាគបីនៃចំនួនសមាជិកព្រឹទ្ធសភាទាំងមូល ។

**មាត្រា ១២.-**

ក្នុងករណីសមាជិកព្រឹទ្ធសភាណា បានប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌជាក់ស្ដែង ក្រសួងមានសមត្ថកិច្ចអាចចោទប្រកាន់ ចាប់ខ្លួន ឃាត់ខ្លួន ឬ ឃុំខ្លួនបាន ហើយត្រូវធ្វើសេចក្ដីរាយការណ៍ជូនព្រឹទ្ធសភា ឬ ជូនគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា នៅចន្លោះសម័យប្រជុំព្រឹទ្ធសភាជាបន្ទាន់ ដើម្បីសម្រេច ។

**មាត្រា ១៣.-**

ក្នុងករណីទាំងអស់ខាងលើនេះ ការឃុំខ្លួន ការចោទប្រកាន់សមាជិកព្រឹទ្ធសភាណាមួយត្រូវផ្អាក ប្រសិនបើព្រឹទ្ធសភាបញ្ចេញមតិឱ្យផ្អាកតាមមតិភាគច្រើនបីភាគបួននៃចំនួនសមាជិកព្រឹទ្ធសភាទាំងមូល ។

**មាត្រា ១៤.-**

សមាជិកព្រឹទ្ធសភាដែលអភ័យឯកសិទ្ធិសភាត្រូវបានលើក ហើយស្ថិតក្នុងការចោទប្រកាន់របស់តុលាការមានសិទ្ធិ និងបុព្វសិទ្ធិដូចសមាជិកព្រឹទ្ធសភាទូទៅ ។

សមាជិកព្រឹទ្ធសភាដែលស្ថិតក្នុងការចាប់ខ្លួន ឬ ឃាត់ខ្លួន ឬ ឃុំខ្លួនជាបណ្ដោះអាសន្ន ត្រូវបាត់បង់សិទ្ធិចូលរួមប្រជុំព្រឹទ្ធសភា និងគណៈកម្មការផ្សេងៗ ប៉ុន្តែមានសិទ្ធិទទួលប្រាក់បំណាច់ វៀរលែងតែប្រាក់បំណាច់ប្រជុំ ប្រាក់បេសកកម្ម និងប្រាក់ប្រេងឥន្ធនៈ ។

សមាជិកព្រឹទ្ធសភាដែលមានសាលក្រមស្ថាពរ ឬ សាលដីកាស្ថាពរសម្រេចថា ជាទណ្ឌិតជាប់ពន្ធនាគារ ត្រូវបាត់បង់ទាំងស្រុងនូវសិទ្ធិ បុព្វសិទ្ធិ និងសមាជិកភាពជាសមាជិកព្រឹទ្ធសភា ។

**មាត្រា ១៥.-**

សមាជិកព្រឹទ្ធសភារូបណាមួយជាទណ្ឌិត ហើយត្រូវបានព្រះមហាក្សត្រលើកលែងទោសសមាជិកព្រឹទ្ធសភារូបនោះនឹងបានទទួលសុពលភាព អភ័យឯកសិទ្ធិសភា និងបុព្វសិទ្ធិឡើងវិញ ។

**មាត្រា ១៦.-**

សមាជិកព្រឹទ្ធសភាដែលមានសាលក្រមស្ថាពរ ឬ សាលដីកាស្ថាពរសម្រេចថាជាជនគ្មានទោស សមាជិកព្រឹទ្ធសភានោះ ត្រូវបានទទួលជាស្វ័យប្រវត្តិនូវអភ័យឯកសិទ្ធិសភានិងបុព្វសិទ្ធិឡើងវិញ ។

## ជំពូកទី ៣
## វិសមិតភាព

**មាត្រា ១៧.-**

*អាណត្តិនៃសមាជិកព្រឹទ្ធសភាមានវិសមិតភាពជាមួយការបំពេញមុខងារសាធារណៈជាសកម្ម ជាមួយមុខងារជាតំណាងរាស្ត្រ និងជាមួយមុខងារជាសមាជិកនៃស្ថាប័នដទៃទៀតដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ និងច្បាប់ជាធរមាន ។*

## ជំពូកទី ៤
## ប្រាក់បំណាច់ ឋានៈ និងបុព្វសិទ្ធិ

**មាត្រា ១៨.-**

*ព្រឹទ្ធសភាមានថវិកាស្វយ័តសម្រាប់ដំណើរការ ។*

*សមាជិកព្រឹទ្ធសភាត្រូវទទួលប្រាក់បំណាច់ ។*

*សមាជិកព្រឹទ្ធសភាមានឋានៈ និងបុព្វសិទ្ធិស្មើនឹងឧត្តមមន្ត្រីផុតលេខនៃព្រះរាជាណាចក្រកម្ពុជា ។*

*សមាជិកព្រឹទ្ធសភាគ្រប់រូប ត្រូវបានទទួលនូវការធានារ៉ាប់រងសង្គម នៅក្នុងអាណត្តិរបស់ខ្លួន ។*

*ក្នុងករណីដែលសមាជិកព្រឹទ្ធសភាទទួលអនិច្ចកម្មនៅក្នុងអាណត្តិ គណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភាត្រូវទទួលបន្ទុករៀបចំពិធីបុណ្យសព និងផ្តល់ប្រាក់បំណាច់ ព្រមទាំងប្រាក់ឧបត្ថម្ភផ្សេងៗគ្រប់យ៉ាងដល់គ្រួសារសព រយៈពេលមួយឆ្នាំទៀត គិតចាប់ពីថ្ងៃទទួលអនិច្ចកម្ម ។*

*គណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភាត្រូវរៀបចំរបបប្រាក់បំណាច់ របបធានារ៉ាប់រងសង្គម របបធានាជម្ងឺ របបប្រាក់សោធននិវត្តន៍ របបបេសកកម្ម និងល័ក្ខខ័ណ្ឌធ្វើការងាររបស់សមាជិកព្រឹទ្ធសភា ។*

**មាត្រា ១៩.-**

សមាជិកព្រឹទ្ធសភាទទួលប្រាក់សោធននិវត្តន៍ ។

ប្រាក់សោធននិវត្តន៍របស់សមាជិកព្រឹទ្ធសភា បើកនៅអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ។

ប្រាក់សោធននិវត្តន៍បើកបានតែមួយកន្លែងគត់ ។

គណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា ត្រូវសម្រេចឱ្យសមាជិកព្រឹទ្ធសភាចូលនិវត្តន៍តាមការស្នើសុំរបស់សាមីខ្លួន ។

**មាត្រា ២០.-**

ល័ក្ខខ័ណ្ឌទាំងឡាយដែលអតីតសមាជិកព្រឹទ្ធសភា ទទួលបានប្រាក់សោធននិវត្តន៍ :

ក-ជាអតីតសមាជិកព្រឹទ្ធសភា ជាអតីតសមាជិករដ្ឋសភាគិតចាប់តាំងពីឆ្នាំ១៩៩៣ មកដែលបានបំពេញការងារជាសមាជិកព្រឹទ្ធសភា ឬ ជាអតីតសមាជិកក្រុមប្រឹក្សាធម្មនុញ្ញគិតចាប់តាំងពីឆ្នាំ១៩៩៨ មកដែលបានមកបំពេញការងារជាសមាជិកព្រឹទ្ធសភា ។

ខ-មានអាយុចាប់ពី ៦០ (ហុកសិប)ឆ្នាំឡើង ។

គ-មិនបានទទួលប្រាក់សោធននិវត្តន៍ពីស្ថាប័នណាមួយរបស់រដ្ឋទេ ។

**មាត្រា២១ ថ្មី.-**

ប្រាក់សោធននិវត្តន៍ប្រចាំខែរបស់និវត្តជនម្នាក់ៗ ត្រូវផ្អែកលើប្រាក់បំណាច់ និងប្រាក់ឧបត្ថម្ភផ្សេងៗគ្រប់យ៉ាង នៃឆ្នាំដែលសមាជិកព្រឹទ្ធសភាបានទទួលខ្ពស់បំផុត ដោយគិតទាំងឋានៈមុខងារផងដែរ កំណត់ស្មើមួយរយភាគរយ ។

ប្រាក់សោធននិវត្តន៍ប្រចាំខែ ត្រូវកំណត់ដោយផ្អែកលើរយៈពេលបំពេញការងារដូចតទៅ ៖

- ពី ១ ឆ្នាំ ដល់ ៣ ឆ្នាំ ទទួលបានសន្ទស្សន៍ ០,៥%
- លើសពី ៣ ឆ្នាំ ដល់ក្រោម ៦ ឆ្នាំ ទទួលបានសន្ទស្សន៍ ១%
- ពី ៦ ឆ្នាំ ដល់ក្រោម ១១ ឆ្នាំ ទទួលបានសន្ទស្សន៍ ២%
- ពី ១១ ឆ្នាំ ដល់ក្រោម ១៦ ឆ្នាំ ទទួលបានសន្ទស្សន៍ ៣%
- ពី ១៦ ឆ្នាំ ឡើងទៅ ទទួលបានសន្ទស្សន៍ ៤% ។

អតីតសមាជិកព្រឹទ្ធសភា ទទួលប្រាក់សោធននិវត្តន៍ប្រចាំខែរហូតដល់ទទួលមរណភាព ។

និវត្តជនជាអតីតសមាជិកព្រឹទ្ធសភា នៅពេលជាប់ជាសមាជិកព្រឹទ្ធសភាឡើងវិញ ឬជាតំណាងរាស្ត្រ ឬត្រូវបានតែងតាំង ឬជ្រើសតាំងជាសមាជិកក្រុមប្រឹក្សាធម្មនុញ្ញមិនត្រូវបានផ្តល់ប្រាក់សោធននិវត្តន៍ទេ ។ សាមីជនត្រូវបើកប្រាក់បំណាច់ជាសមាជិកព្រឹទ្ធសភា ឬជាតំណាងរាស្ត្រ ឬជាសមាជិកក្រុមប្រឹក្សាធម្មនុញ្ញជាធម្មតា ហើយនៅពេលចប់អាណត្តិទើបសាមីជនបើកប្រាក់សោធននិវត្តន៍វិញសាជាថ្មី ដោយកែសម្រួលសន្ទស្សន៍ទៅតាមអតីតភាព ។

**មាត្រា ២២.-**

អតីតសមាជិកព្រឹទ្ធសភាដែលមិនជាប់ឆ្នោតឡើងវិញ ក្រោយពីមានអាយុគ្រប់ ៦០(ហុកសិប) ឆ្នាំ អាចទទួលបានប្រាក់សោធននិវត្តន៍ ដោយបើកផ្តាច់ត្រឹមរយៈពេលមួយឆ្នាំគត់បាន ។

**មាត្រា ២៣.-**

សមាជិកព្រឹទ្ធសភាមានអ្នកជំនួយការផ្ទាល់មួយចំនួនដែលជួយធ្វើការងារ តាមល័ក្ខខ័ណ្ឌបុគ្គលិកជាប់កិច្ចសន្យាដែលកំណត់ដោយគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា ឯប្រាក់កម្រៃជាបន្ទុកថវិកាព្រឹទ្ធសភា ។

ដើម្បីមានភាពងាយស្រួលក្នុងការបំពេញការងារ អគ្គលេខាធិការដ្ឋានព្រឹទ្ធសភាជួយដល់សមាជិកព្រឹទ្ធសភា តាមបែបបទកំណត់ក្នុងបទបញ្ជាផ្ទៃក្នុងនៃព្រឹទ្ធសភា ។

**មាត្រា ២៤.-**

សមាជិកព្រឹទ្ធសភាក្នុងតំណែងត្រូវទទួលបាននូវៈ

- ប័ណ្ណសំគាល់អភ័យឯកសិទ្ធិ
- រូបសញ្ញាព្រឹទ្ធសភាសម្រាប់ពាក់លើអាវ
- រូបសញ្ញាបារមីរបស់ព្រឹទ្ធសភា
- ផ្លាករថយន្តព្រឹទ្ធសភា
- លិខិតឆ្លងដែនការទូតផ្ទាល់ខ្លួន សហព័ទ្ធ និងកូនអាយុក្រោម ១៨ ឆ្នាំ

- ឯកសណ្ឋានព្រឹទ្ធសភា
- គ្រឿងឥស្សរិយយសពីរដង ក្នុងមួយអាណត្តិ
- ការធានារ៉ាប់រងជម្ងឺនៅក្នុងមន្ទីរពេទ្យរដ្ឋនៅក្នុងព្រះរាជាណាចក្រកម្ពុជា ដោយថវិការបស់ព្រឹទ្ធសភា ។

**មាត្រា ២៥.-**

មន្ត្រីរាជការស៊ីវិល ឬ កងកម្លាំងប្រដាប់អាវុធ ដែលជាប់ឆ្នោតជាសមាជិកព្រឹទ្ធសភាត្រូវបានឡើងឋានន្តរស័ក្តិឡើងថ្នាក់ដោយស្វ័យប្រវត្តិ និងរក្សាអតីតភាព សម្រាប់ទទួលសោធននិវត្តន៍ ។

**មាត្រា ២៦.-**

សមាជិក សមាជិកាព្រឹទ្ធសភាក្នុងតំណែងត្រូវបានទទួលងារជា ឯកឧត្តម ឬ លោកជំទាវ ។ អតីតសមាជិក សមាជិកាព្រឹទ្ធសភា ក្រោយពេលដែលបានបញ្ចប់អាណត្តិហើយត្រូវបានរក្សាងារជាឯកឧត្តមអតីតសមាជិកព្រឹទ្ធសភា ឬ លោកជំទាវអតីតសមាជិកាព្រឹទ្ធសភា ។

# ជំពូកទី ៥
# អវសានប្បញ្ញត្តិ

**មាត្រា ២៧.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងច្បាប់នេះ ត្រូវទុកជានិរាករណ៍ ។

# កំណត់សម្គាល់

# កំណត់សម្គាល់

ច្បាប់ស្តីពីលក្ខន្តិកៈសមាជិកព្រឹទ្ធសភា ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០១០៨/០០១ចុះថ្ងៃទី១៨ ខែមករា ឆ្នាំ២០០៨ ត្រូវបានធ្វើវិសោធនកម្មចំនួនមួយលើកគឺ មាត្រា២១ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/១២១៥/០១២ ចុះថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០១៥ ។

# ឧបសម្ព័ន្ធ

# ឧបសម្ព័ន្ធ

ដើម្បីសម្រួលដល់ការសិក្សា ក៏ដូចជាបង្កភាពងាយស្រួលក្នុងការអានច្បាប់ស្តីពីលក្ខន្តិកៈសមាជិកព្រឹទ្ធសភា ការបោះពុម្ពនេះ មានរៀបចំភ្ជាប់ជាមួយនូវ ៖

១-ច្បាប់ស្តីពី លក្ខន្តិកៈសមាជិកព្រឹទ្ធសភា ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រម លេខ នស/រកម/០១០៨/០០១ ចុះថ្ងៃទី ១៨ ខែមករា ឆ្នាំ២០០៨ ។

២-ច្បាប់ស្តីពី វិសោធនកម្មមាត្រា២១ នៃ ច្បាប់ស្តីពី លក្ខន្តិកៈសមាជិកព្រឹទ្ធសភា ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រម លេខ នស/រកម/១២១៥/០១២ ចុះថ្ងៃទី ១១ ខែធ្នូ ឆ្នាំ២០១៥ ។

នស/រកម/០១០៨/០០១

# ព្រះរាជក្រម

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ប្រកាសឱ្យប្រើ

ច្បាប់ ស្តីពីលក្ខន្តិកៈសមាជិកព្រឹទ្ធសភា ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០០៧ នាសម័យប្រជុំរដ្ឋសភា លើកទី ៧ នីតិកាលទី ៣ និងដែលព្រឹទ្ធសភាបានយល់ស្របតាមទម្រង់ និងគតិនៃច្បាប់នេះទាំងស្រុង ដោយគ្មានការកែប្រែអ្វីឡើយ កាលពីថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០០៧ នាសម័យប្រជុំពេញអង្គព្រឹទ្ធសភា លើកទី ៤ នីតិកាលទី ២ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅនេះ ៖

# ច្បាប់

# ស្តីពី

# លក្ខន្តិកៈសមាជិកព្រឹទ្ធសភា

ROYAUME DU CAMBODGE
MINISTRE DU PALAIS ROYAL

# ជំពូកទី ១

# បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

ច្បាប់នេះមានគោលដៅកំណត់នូវអភ័យឯកសិទ្ធិសភា ឋានៈ បុព្វសិទ្ធិ វិសមិតភាព និង លក្ខខ័ណ្ឌចាំបាច់នានា ដើម្បីធានាជូនដល់សមាជិកព្រឹទ្ធសភា ក្នុងការបំពេញភារកិច្ចស្រប តាមរដ្ឋធម្មនុញ្ញ ច្បាប់ និង លិខិតបទដ្ឋាននៃព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា ២.-**

សមាជិកព្រឹទ្ធសភាក្នុងព្រឹទ្ធសភា គឺជាតំណាងរបស់ប្រជាជាតិខ្មែរទាំងមូល ពុំមែនគ្រាន់ តែជាតំណាងឱ្យភូមិភាគរបស់ខ្លួននោះទេ ។

**មាត្រា ៣.-**

សមាជិកព្រឹទ្ធសភាមានអាណត្តិ ៦ ឆ្នាំ (ប្រាំមួយឆ្នាំ)ហើយត្រូវផុតកំណត់នៅពេលសមា- ជិកព្រឹទ្ធសភាថ្មីចូលកាន់តំណែង ។

# ជំពូកទី ២

# អភ័យឯកសិទ្ធិសភា

**មាត្រា ៤.-**

សមាជិកព្រឹទ្ធសភាមានអភ័យឯកសិទ្ធិសភា ។ អភ័យឯកសិទ្ធិសភា ត្រូវបានចែកចេញ ជាពីរផ្នែក :

-ការធានាក្នុងការបញ្ចេញយោបល់ ឬ ការបញ្ចេញមតិក្នុងការអនុម័តទាំងឡាយ របស់សមាជិកព្រឹទ្ធសភា នៅក្នុងក្របខ័ណ្ឌនៃការបំពេញតួនាទីជាសមាជិកព្រឹទ្ធសភា គឺជា អភ័យឯកសិទ្ធិផាច់ខាត ។

-ការធានាមិនឱ្យមានការចោទប្រកាន់ ការចាប់ខ្លួន ឬ ការឃុំខ្លួនសមាជិកព្រឹទ្ធ- សភាណាមួយ គឺជាអភ័យឯកសិទ្ធិដោយប្រៀប ។

**មាត្រា ៥.—**

សមាជិកព្រឹទ្ធសភា មិនអាចឆ្លៀតប្រើអភ័យឯកសិទ្ធិសភានេះដោយរំលោភ នាំឱ្យប៉ះពាល់ ដល់កិត្តិយសរបស់បុគ្គលដទៃ ដល់ទំនៀមទំលាប់ល្អរបស់សង្គម ដល់សណ្តាប់ធ្នាប់សាធារណៈ និងដល់សន្តិសុខជាតិបានឡើយ ។

**មាត្រា ៦.—**

សមាជិកព្រឹទ្ធសភា ត្រូវគោរពបទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភានៃព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា ៧.—**

សមាជិកព្រឹទ្ធសភាដែលបានប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌនឹងអាចអនុញ្ញាតបើកឱ្យធ្វើការចោទប្រកាន់ ការចាប់ខ្លួន ការឃាត់ខ្លួន ឬ ការឃុំខ្លួនតាមច្បាប់ និងនីតិវិធីបាន លុះត្រាតែមានការលើកអភ័យឯកសិទ្ធិសភាជាមុនសិន ។

**មាត្រា ៨.—**

សេចក្តីស្នើសុំលើកអភ័យឯកសិទ្ធិសភារបស់សមាជិកព្រឹទ្ធសភារូបណាមួយ ត្រូវធ្វើឡើងដោយអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ តាមរយៈរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ដោយមានភ្ជាប់សេចក្តីថ្លែងហេតុមកជាមួយផង ផ្ញើជូនប្រធានព្រឹទ្ធសភា ។

**មាត្រា ៩.—**

ការលើកអភ័យឯកសិទ្ធិសភាក្នុងរយៈពេលសម័យប្រជុំព្រឹទ្ធសភា ត្រូវអនុវត្តតាមនីតិវិធីខាងក្រោមនេះ :

-ព្រឹទ្ធសភាអាចប្រជុំជាសម្ងាត់តាមការស្នើសុំពីប្រធាន ឬ ពីសមាជិកព្រឹទ្ធសភាចំនួនមួយភាគដប់យ៉ាងតិច ពីព្រះមហាក្សត្រ ពីនាយករដ្ឋមន្ត្រី ឬ ពីប្រធានរដ្ឋសភា ។

-ក្រុមប្រជុំលើសពី ពីរភាគបីនៃសមាជិកព្រឹទ្ធសភាទាំងមូល ។

-ការអនុម័តតាមមតិភាគច្រើនពីរភាគបីនៃចំនួនសមាជិកព្រឹទ្ធសភាទាំងមូល ។

**មាត្រា ១០.—**

ការលើកអភ័យឯកសិទ្ធិសភាក្នុងចន្លោះសម័យប្រជុំព្រឹទ្ធសភា គណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភាត្រូវប្រជុំ និងអនុម័តស្របតាមបទបញ្ជាផ្ទៃក្នុងនៃព្រឹទ្ធសភា ។

**មាត្រា ១១.-**

សេចក្តីសម្រេចរបស់គណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា ត្រូវដាក់ជូនសម័យប្រជុំព្រឹទ្ធ-សភាខាងមុខ ដើម្បីអនុម័តតាមមតិភាគច្រើនពីរភាគបីនៃចំនួនសមាជិកព្រឹទ្ធសភាទាំងមូល ។

**មាត្រា ១២.-**

ក្នុងករណីសមាជិកព្រឹទ្ធសភាណា បានប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌជាក់ស្តែង ក្រសួងមានសមត្ថកិច្ចអាចចោទប្រកាន់ ចាប់ខ្លួន ឃាត់ខ្លួន ឬ ឃុំខ្លួនបាន ហើយត្រូវធ្វើសេចក្តីរាយការណ៍ជូនព្រឹទ្ធសភា ឬ ជូនគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា នៅចន្លោះសម័យប្រជុំព្រឹទ្ធ-សភាជាបន្ទាន់ ដើម្បីសម្រេច ។

**មាត្រា ១៣.-**

ក្នុងករណីទាំងអស់ខាងលើនេះ ការឃុំខ្លួន ការចោទប្រកាន់សមាជិកព្រឹទ្ធសភាណាមួយត្រូវផ្អាក ប្រសិនបើព្រឹទ្ធសភាបញ្ចេញមតិឱ្យផ្អាកតាមមតិភាគច្រើនបីភាគបួននៃចំនួនសមាជិកព្រឹទ្ធសភាទាំងមូល ។

**មាត្រា ១៤.-**

សមាជិកព្រឹទ្ធសភាដែលអភ័យឯកសិទ្ធិសភាត្រូវបានលើក ហើយស្ថិតក្នុងការចោទប្រកាន់របស់តុលាការមានសិទ្ធិ និងបុព្វសិទ្ធិដូចសមាជិកព្រឹទ្ធសភាទូទៅ ។

សមាជិកព្រឹទ្ធសភាដែលស្ថិតក្នុងការចាប់ខ្លួន ឬ ឃាត់ខ្លួន ឬ ឃុំខ្លួនជាបណ្តោះអាសន្នត្រូវបាត់បង់សិទ្ធិចូលរួមប្រជុំព្រឹទ្ធសភា និងគណៈកម្មការផ្សេងៗ ប៉ុន្តែមានសិទ្ធិទទួលប្រាក់បំណាច់ វៀរលែងតែប្រាក់បំណាច់ប្រជុំ ប្រាក់បេសកកម្ម និងប្រាក់ប្រេងឥន្ធនៈ ។

សមាជិកព្រឹទ្ធសភាដែលមានសាលក្រមស្ថាពរ ឬ សាលដីកាស្ថាពរសម្រេចថា ជាទណ្ឌិតជាប់ពន្ធនាគារ ត្រូវបាត់បង់ទាំងស្រុងនូវសិទ្ធិ បុព្វសិទ្ធិ និងសមាជិកភាពជាសមាជិកព្រឹទ្ធសភា ។

**មាត្រា ១៥.-**

សមាជិកព្រឹទ្ធសភារូបណាមួយជាទណ្ឌិត ហើយត្រូវបានព្រះមហាក្សត្រលើកលែងទោស សមាជិកព្រឹទ្ធសភារូបនោះនឹងបានទទួលសុពលភាព អភ័យឯកសិទ្ធិសភា និងបុព្វសិទ្ធិឡើង

**មាត្រា ១៦.-**

សមាជិកព្រឹទ្ធសភាដែលមានសាលក្រមស្ថាពរ ឬ សាលដីកាស្ថាពរសម្រេចថាជាជនគ្មានទោស សមាជិកព្រឹទ្ធសភានោះ ត្រូវបានទទួលជាស្វ័យប្រវត្តិនូវអភ័យឯកសិទ្ធិសភានិងបុព្វសិទ្ធិឡើងវិញ ។

## ជំពូកទី ៣

## វិសមិតភាព

**មាត្រា ១៧.-**

អាណត្តិនៃសមាជិកព្រឹទ្ធសភាមានវិសមិតភាពជាមួយការបំពេញមុខងារសាធារណៈជាសកម្ម ជាមួយមុខងារជាតំណាងរាស្ត្រ និងជាមួយមុខងារជាសមាជិកនៃស្ថាប័នដទៃទៀតដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ និងច្បាប់ជាធរមាន ។

## ជំពូកទី ៤

## ប្រាក់បំណាច់ ឋានៈ និងបុព្វសិទ្ធិ

**មាត្រា ១៨.-**

ព្រឹទ្ធសភាមានថវិកាស្វយ័តសម្រាប់ដំណើរការ ។

សមាជិកព្រឹទ្ធសភាត្រូវទទួលប្រាក់បំណាច់ ។

សមាជិកព្រឹទ្ធសភាមានឋានៈ និងបុព្វសិទ្ធិស្មើនឹងឧត្តមមន្ត្រីផុតលេខនៃព្រះរាជាណាចក្រកម្ពុជា ។

សមាជិកព្រឹទ្ធសភាគ្រប់រូប ត្រូវបានទទួលនូវការធានារ៉ាប់រងសង្គម នៅក្នុងអាណត្តិរបស់ខ្លួន ។

ក្នុងករណីដែលសមាជិកព្រឹទ្ធសភាទទួលអនិច្ចកម្មនៅក្នុងអាណត្តិ គណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា ត្រូវទទួលបន្ទុករៀបចំពិធីបុណ្យសព និងផ្តល់ប្រាក់បំណាច់ ព្រមទាំងប្រាក់ឧបត្ថម្ភផ្សេងៗគ្រប់យ៉ាងដល់គ្រួសារសព រយៈពេលមួយឆ្នាំទៀត គិតចាប់ពីថ្ងៃទទួលអនិច្ចកម្ម ។

គណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភាត្រូវរៀបចំរបបប្រាក់បំណាច់ របបធានារ៉ាប់រងសង្គម របបធានាជម្ងឺ របបប្រាក់សោធននិវត្តន៍ របបបេសកកម្ម និងល័ក្ខខ័ណ្ឌធ្វើការងាររបស់សមាជិកព្រឹទ្ធសភា ។

**មាត្រា ១៩.-**

សមាជិកព្រឹទ្ធសភាទទួលប្រាក់សោធននិវត្តន៍ ។

ប្រាក់សោធននិវត្តន៍របស់សមាជិកព្រឹទ្ធសភា បើកនៅអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ។

ប្រាក់សោធននិវត្តន៍បើកបានតែមួយកន្លែងគត់ ។

គណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា ត្រូវសម្រេចឱ្យសមាជិកព្រឹទ្ធសភាចូលនិវត្តន៍តាមការស្នើសុំរបស់សាមីខ្លួន ។

**មាត្រា ២០.-**

ល័ក្ខខ័ណ្ឌទាំងឡាយដែលអតីតសមាជិកព្រឹទ្ធសភាទទួលបានប្រាក់សោធននិវត្តន៍ :

ក-ជាអតីតសមាជិកព្រឹទ្ធសភា ជាអតីតសមាជិករដ្ឋសភាគិតចាប់តាំងពីឆ្នាំ១៩៩៣ មកដែលបានមកបំពេញការងារជាសមាជិកព្រឹទ្ធសភា ឬ ជាអតីតសមាជិកក្រុមប្រឹក្សាធម្មនុញ្ញគិតចាប់តាំងពីឆ្នាំ ១៩៩៨ មកដែលបានមកបំពេញការងារជាសមាជិកព្រឹទ្ធសភា ។

ខ-មានអាយុចាប់ពី ៦០ (ហុកសិប)ឆ្នាំឡើង ។

គ-មិនបានទទួលប្រាក់សោធននិវត្តន៍ពីស្ថាប័នណាមួយរបស់រដ្ឋទេ ។

**មាត្រា ២១.-**

រូបមន្តសម្រាប់គណនា រៀបចំរបបសោធននិវត្តន៍របស់អតីតសមាជិកព្រឹទ្ធសភា ត្រូវផ្អែកលើប្រាក់បំណាច់សមាជិកព្រឹទ្ធសភា និងប្រាក់ឧបត្ថម្ភផ្សេងៗគ្រប់យ៉ាងរយៈពេលមួយឆ្នាំរបស់សមាជិកព្រឹទ្ធសភាម្នាក់ៗនៃឆ្នាំចុងក្រោយកំណត់ស្មើនឹង ១០០ ៜ(មួយរយភាគរយ) ។

ប្រាក់សោធននិវត្តន៍ប្រចាំខែត្រូវកំណត់ដោយផ្អែកលើរយៈពេលបំពេញការងារដូចតទៅ :

| | |
|---|---|
| -ពី ១ ឆ្នាំ ដល់ ៣ ឆ្នាំ ទទួលបានសន្ទស្សន៍ | ០,៥ ៜ |
| -លើសពី ៣ ឆ្នាំ ដល់ក្រោម ៦ ឆ្នាំ ទទួលបានសន្ទស្សន៍ | ១ ៜ |
| -ពី ៦ ឆ្នាំ ដល់ក្រោម ១១ ឆ្នាំ ទទួលបានសន្ទស្សន៍ | ២ ៜ |

ព្រះរាជាណាចក្រកម្ពុជា ... CAMBODGE ... CENTRE ... 

-ពី ១១ ឆ្នាំ ដល់ក្រោម ១៦ ឆ្នាំ ទទួលបានសន្ទស្សន៍ ៣ ៕

-ពី ១៦ ឆ្នាំ ឡើងទៅទទួលបានសន្ទស្សន៍ ៤ ៕

អតីតសមាជិកព្រឹទ្ធសភាទទួលប្រាក់សោធននិវត្តន៍ប្រចាំខែរហូតដល់ទទួលមរណភាព វៀរលែងតែត្រូវបានជាប់ឆ្នោតជាសមាជិកព្រឹទ្ធសភា ។

**មាត្រា ២២.–**

អតីតសមាជិកព្រឹទ្ធសភាដែលមិនជាប់ឆ្នោតឡើងវិញ ក្រោយពីមានអាយុគ្រប់៦០(ហុកសិប) ឆ្នាំ អាចទទួលបានប្រាក់សោធននិវត្តន៍ ដោយបើកផ្តាច់ត្រឹមរយៈពេលតែមួយឆ្នាំតែប៉ុណ្ណោះ។

**មាត្រា ២៣.–**

សមាជិកព្រឹទ្ធសភាមានអ្នកជំនួយការផ្ទាល់មួយចំនួនដែលជួយធ្វើការងារ ពោមល័ក្ខខ័ណ្ឌបុគ្គលិកជាប់កិច្ចសន្យាដែលកំណត់ដោយគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា ឯប្រាក់កម្រៃជាបន្ទុកថវិកាព្រឹទ្ធសភា ។

ដើម្បីមានភាពងាយស្រួលក្នុងការបំពេញការងារ អគ្គលេខាធិការដ្ឋានព្រឹទ្ធសភាជួយដល់សមាជិកព្រឹទ្ធសភា តាមបែបបទកំណត់ក្នុងបទបញ្ជាផ្ទៃក្នុងនៃព្រឹទ្ធសភា ។

**មាត្រា ២៤.–**

សមាជិកព្រឹទ្ធសភាក្នុងតំណែងត្រូវទទួលបាននូវ :

-ប័ណ្ណសំគាល់អភ័យឯកសិទ្ធិ

-រូបសញ្ញាព្រឹទ្ធសភាសម្រាប់ពាក់លើអាវ

-រូបសញ្ញាបារមីរបស់ព្រឹទ្ធសភា

-ផ្លាករថយន្តព្រឹទ្ធសភា

-លិខិតឆ្លងដែនការទូតផ្ទាល់ខ្លួន សហព័ទ្ធ និងកូនអាយុក្រោម.១៨ ឆ្នាំ

-ឯកសណ្ឋានព្រឹទ្ធសភា

-គ្រឿងឥស្សរិយយសពីរថង ក្នុងមួយអាណត្តិ

-ការធានារ៉ាប់រងជម្ងឺនៅក្នុងមន្ទីរពេទ្យរដ្ឋនៅក្នុងព្រះរាជាណាចក្រកម្ពុជា ដោយថវិការបស់ព្រឹទ្ធសភា ។

ROYAUME DU CAMBODGE
REGISTRE DU PALAIS ROYAL

**មាត្រា ២៥.-**

មន្ត្រីរាជការស៊ីវិល ឬ កងកម្លាំងប្រដាប់អាវុធ ដែលជាប់ឆ្នោតជាសមាជិកព្រឹទ្ធសភា ត្រូវបានឡើងឋានន្តរសក្តិ ឡើងថ្នាក់ដោយស្វ័យប្រវត្តិ និងរក្សាអតីតភាព សម្រាប់ទទួលសោធន-និវត្តន៍ ។

**មាត្រា ២៦.-**

សមាជិក សមាជិកាព្រឹទ្ធសភាក្នុងតំណែងត្រូវបានទទួលងារជា ឯកឧត្តម ឬ លោកជំទាវ ។ អតីតសមាជិក សមាជិកាព្រឹទ្ធសភា ក្រោយពេលដែលបានបញ្ចប់អាណត្តិហើយត្រូវបានរក្សាងារជាឯកឧត្តមអតីតសមាជិកព្រឹទ្ធសភា ឬ លោកជំទាវអតីតសមាជិកាព្រឹទ្ធសភា ។

## ជំពូកទី ៥

## អវសានប្បញ្ញត្តិ

**មាត្រា ២៧.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងច្បាប់នេះ ត្រូវទុកជានិរាករណ៍ ។

ធ្វើនៅព្រះបរមរាជវាំងរាជធានីភ្នំពេញថ្ងៃទី ១៨ ខែមករា ឆ្នាំ ២០០៨

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

៣ស/៧.០៥០១.០៣៩

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ
សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ
នាយករដ្ឋមន្ត្រី
**ហត្ថលេខា**
**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

លេខ : ៦១ ច.ល
ចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី២៤ ខែមករា ឆ្នាំ២០០៨
អគ្គលេខាធិការរាជរដ្ឋាភិបាល
ជិនរកន

# ព្រះរាជក្រម

នស/រកម/១២១៥/០១៧

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១០៨/០០១ ចុះថ្ងៃទី១៨ ខែមករា ឆ្នាំ២០០៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីលក្ខន្តិកៈសមាជិកព្រឹទ្ធសភា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

## ប្រកាសឲ្យប្រើ

ច្បាប់ស្តីពីវិសោធនកម្មមាត្រា២១ នៃច្បាប់ស្តីពីលក្ខន្តិកៈសមាជិកព្រឹទ្ធសភា ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី២៦ ខែតុលា ឆ្នាំ២០១៥ នាសម័យប្រជុំរដ្ឋសភាលើកទី៥ នីតិកាលទី៥ ហើយដែលព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់លើទម្រង់និងគតិច្បាប់នេះទាំងស្រុងកាលពីថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០១៥ នាសម័យប្រជុំជាវិសាមញ្ញ នីតិកាលទី៣ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅ ៖

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL •
ព្រះបរមរាជវាំង

# ច្បាប់

# ស្តីពី

# វិសោធនកម្មមាត្រា ២១

# នៃច្បាប់ស្តីពីលក្ខន្តិកៈសមាជិកព្រឹទ្ធសភា

ROYAUME DU CAMBODGE • LE MINISTERE DU PALAIS ROYAL

**មាត្រាតែមួយ.-**

មាត្រា ២១ នៃច្បាប់ស្តីពីលក្ខន្តិកៈសមាជិកព្រឹទ្ធសភា ដែលប្រកាសឲ្យប្រើដោយព្រះរាជក្រម លេខៈ នស/រកម/០១០៨/០០១ ចុះថ្ងៃទី ១៨ ខែ មករា ឆ្នាំ ២០០៨ ត្រូវបានធ្វើវិសោធនកម្មដូចខាងក្រោម ៖

**មាត្រា ២១ ថ្មី.-**

ប្រាក់សោធននិវត្តន៍ប្រចាំខែរបស់និវត្តជនម្នាក់ៗ ត្រូវផ្អែកលើប្រាក់បំណាច់ និងប្រាក់ឧបត្ថម្ភផ្សេងៗគ្រប់យ៉ាង នៃឆ្នាំដែលសមាជិកព្រឹទ្ធសភាបានទទួលខ្ពស់បំផុត ដោយគិតទាំងឋានៈមុខងារផងដែរ កំណត់ស្មើមួយរយភាគរយ ។

ប្រាក់សោធននិវត្តន៍ប្រចាំខែ ត្រូវកំណត់ដោយផ្អែកលើរយៈពេលបំពេញការងារដូចតទៅ ៖

-ពី ១ ឆ្នាំ ដល់ ៣ ឆ្នាំ ទទួលបានសន្ទស្សន៍ ០,៥%

-លើសពី ៣ ឆ្នាំ ដល់ក្រោម ៦ ឆ្នាំ ទទួលបានសន្ទស្សន៍ ១%

-ពី ៦ ឆ្នាំ ដល់ក្រោម ១១ ឆ្នាំ ទទួលបានសន្ទស្សន៍ ២%

-ពី ១១ ឆ្នាំ ដល់ក្រោម ១៦ ឆ្នាំ ទទួលបានសន្ទស្សន៍ ៣%

-ពី ១៦ ឆ្នាំ ឡើងទៅ ទទួលបានសន្ទស្សន៍ ៤% ។

អតីតសមាជិកព្រឹទ្ធសភា ទទួលប្រាក់សោធននិវត្តន៍ប្រចាំខែរហូតដល់ទទួលមរណភាព ។

និវត្តជនជាអតីតសមាជិកព្រឹទ្ធសភា នៅពេលជាប់ជាសមាជិកព្រឹទ្ធសភាឡើងវិញ ឬជាតំណាងរាស្ត្រ ឬត្រូវបានតែងតាំង ឬជ្រើសតាំងជាសមាជិកក្រុមប្រឹក្សាធម្មនុញ្ញមិនត្រូវបានផ្តល់ប្រាក់សោធននិវត្តន៍ទេ ។ សាមីជនត្រូវបើកប្រាក់បំណាច់ជាសមាជិកព្រឹទ្ធសភា ឬជាតំណាងរាស្ត្រ ឬជាសមាជិកក្រុមប្រឹក្សាធម្មនុញ្ញជាធម្មតា ហើយនៅពេលចប់អាណត្តិទើបសាមីជនបើកប្រាក់សោធននិវត្តន៍វិញសាជាថ្មី ដោយកែសម្រួលសន្ទស្សន៍ទៅតាមអតីតភាព ។

ធ្វើនៅព្រះបរមរាជវាំង ថ្ងៃទី ១១ ខែ [illegible] ឆ្នាំ២០១៥

[illegible]

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

**នរោត្តម សីហមុនី**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ

សូមឡាយព្រះហស្តលេខា

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

លេខៈ ១១៧៣ស.ណ

សំណៅចំលងចេញពីច្បាប់ដើម

រាជធានីភ្នំពេញ ថ្ងៃទី១៥ ខែ [illegible] ឆ្នាំ២០១៥

អគ្គលេខាធិការរាជរដ្ឋាភិបាល

**សយ សុខា**

# សមាសភាព
# គណៈកម្មការពិសេស
# រៀបចំសេចក្តីស្នើច្បាប់ ស្តីពីលក្ខន្តិកៈសមាជិកព្រឹទ្ធសភា

# សមាសភាពគណៈកម្មការពិសេស
# រៀបចំសេចក្តីស្នើច្បាប់ ស្តីពីលក្ខន្តិកៈសមាជិក
# ព្រឹទ្ធសភា

*(សេចក្តីសម្រេចរបស់ព្រឹទ្ធសភាលេខៈ១២៩/០៩០៦/ពស/សរ ចុះថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០០៦ និងលេខៈ១៣០/១០០៦/ពស/រស ចុះថ្ងៃទី០៣ ខែតុលា ឆ្នាំ២០០៦)*

| | | |
|---|---|---|
| ១- | ឯកឧត្តម **អ៊ុក ប៊ុនឈឿន** | ប្រធាន |
| ២- | ឯកឧត្តម **ជា ចេដ្ឋ** | អនុប្រធាន |
| ៣- | ឯកឧត្តម **គង់ សារាជ** | លេខាធិការ |
| ៤- | លោកជំទាវ **ម៉ែន ម៉ាលី** | សមាជិកា |
| ៥- | ឯកឧត្តម **ចាន់ គិន** | សមាជិក |
| ៦- | លោកជំទាវ **ទី បូរ៉ាស៊ី** | សមាជិកា |
| ៧- | ឯកឧត្តម **គង់ គាំ** | សមាជិក |
| ៨- | លោកជំទាវ **ខ្លូត ធងផ្កា** | សមាជិកា |
| ៩- | ឯកឧត្តម **សោ ម៉ូចាចា** | សមាជិក ។ |

## ក្រុមមន្ត្រីអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
## ដែលនៅអមគណៈកម្មការពិសេស

| | |
|---|---|
| ១-ឯកឧត្តម **ឡោក សាយ** | ប្រធាននាយកដ្ឋាន ហិរញ្ញវត្ថុ |
| ២-ឯកឧត្តម **គឹម លី** | ប្រធាននាយកដ្ឋាន ស្រាវជ្រាវច្បាប់ |
| ៣-ឯកឧត្តម **ប៊ុន ទុន្នា** | ប្រធាននាយកដ្ឋាន នីតិវិធី |
| ៤-ឯកឧត្តម **គឹម សុផា** | អនុប្រធាននាយកដ្ឋាន ហិរញ្ញវត្ថុ |
| ៥-លោក **ជាវ គឹមសេង** | ប្រធាននាយកដ្ឋាន ជំនួយការគណៈកម្មការ |
| ៦-លោកស្រី **ស្ងួន ពុធថាវី** | អនុប្រធាននាយកដ្ឋាន នីតិវិធី |
| ៧- លោក **យ៉ាន់ វ៉ាន់ឌីលុច** | អនុប្រធាននាយកដ្ឋាន ស្រាវជ្រាវច្បាប់ |
| ៨-លោក **ពៅ ថារី** | ប្រធានការិយាល័យ នីតិវិធី |
| ៩-លោកស្រី **យ៉េម កាន់នីកា** | ប្រធានការិយាល័យ ច្បាប់អន្តរជាតិ |

| | |
|---|---|
| ១០-លោក **គុយ គួច** | ប្រធានការិយាល័យច្បាប់ព្រហ្មទណ្ឌ និងរដ្ឋប្បវេណី |
| ១១-លោក **ឈុប គុជ** | ប្រធានការិយាល័យច្បាប់ឯកជន |
| ១២-លោក **ឡៅ សិទ្ធិរ៉ូ** | ប្រធានការិយាល័យកណ្តាលទី២ នាយកដ្ឋានជំនួយការគណៈកម្មការ |
| ១៣-លោក **សួ មីនីរដ្ឋ** | ប្រធានការិយាល័យកណ្តាលទី៣ នាយកដ្ឋានជំនួយការគណៈកម្មការ |
| ១៤-លោក**ម៉ាក់ គឹមឡុង** | ប្រធានលេខាធិការដ្ឋានអមគណៈកម្មការទី៦ |
| ១៥-លោក**គុប សំគី** | អនុប្រធានការិយាល័យច្បាប់សាធារណៈ |
| ១៦-លោកស្រី **នួ ឈិន** | អនុប្រធានការិយាល័យច្បាប់អន្តរជាតិ ។ |

# សមាសភាពគណៈកម្មការពិសេស
# រៀបចំសេចក្តីស្នើវិសោធនកម្មច្បាប់ស្តីពីលក្ខន្តិកៈ
# សមាជិកព្រឹទ្ធសភា

(*សេចក្តីសម្រេចរបស់ព្រឹទ្ធសភាលេខ:០២៥/០២១៥/ពស/សរ ចុះថ្ងៃទី២១ ខែមេសាឆ្នាំ២០១៥*)

| | | |
|---|---|---|
| ១- | ឯកឧត្តម **អ៊ុក ប៊ុនឈឿន** | ប្រធាន |
| ២- | ឯកឧត្តម **ជា ដេឌ្ឋ** | អនុប្រធាន |
| ៣- | ឯកឧត្តម **គង់ សារាជ** | លេខាធិការ |
| ៤- | ឯកឧត្តម **ប៊ូ ថង** | សមាជិក |
| ៥- | ឯកឧត្តម **នៃ ប៉េណា** | សមាជិក |
| ៦- | លោកជំទាវ **ទី បូរ៉ាស៊ី** | សមាជិកា |
| ៧- | លោកជំទាវ **មាន សំអាន** | សមាជិកា |
| ៨- | ឯកឧត្តម **គង់ គាំ** | សមាជិក |
| ៩- | ឯកឧត្តម **ម៉ុង ឫទ្ធី** | សមាជិក |
| ១០- | ឯកឧត្តម **ហុង សុខហួរ** | សមាជិក ។ |

## ក្រុមមន្ត្រីអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
## ដែលនៅអមគណៈកម្មការពិសេស

| | |
|---|---|
| ១- ឯកឧត្តម **អ៊ុំ សារិទ្ធ** | *អគ្គលេខាធិការ នៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា* |
| ២- ឯកឧត្តម **ម៉ុន ឫទ្ធា** | *អគ្គនាយក នៃអគ្គនាយកដ្ឋានសេវាច្បាប់ និងសមូហភាពដែនដី* |
| ៣-ឯកឧត្តម **ឈឹម ព្រះខ័ន** | *អគ្គនាយក នៃអគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ* |
| ៤-លោកជំទាវ**ស្ងួន ពុធថាវី** | *អគ្គនាយិការង នៃអគ្គនាយកដ្ឋានសេវាច្បាប់ និងសមូហភាពដែនដី* |
| ៥-លោក **យិន យូវ៉ាន់** | *ប្រធាននាយកដ្ឋាននីតិវិធី* |
| ៦- លោក **នៃ នីន** | *ប្រធានលេខាធិការដ្ឋានអមគណៈកម្មការទី៦ ព្រឹទ្ធសភា* |
| ៧-លោក **ហ៊ួយ វ៉ាន់ឌី** | *ប្រធានលេខាធិការដ្ឋានអមគណៈកម្មការទី២ ព្រឹទ្ធសភា ។* |

# LAW ON STATUTE OF SENATOR

## Chapter I
## General Provision

**Article 1:**
This law is to define the immunity, status, privilege, incompatibility and necessary conditions for ensuring that Senators are able to perform their duties in accordance with the Constitution, laws and legal instruments of the Kingdom of Cambodia.

**Article 2:**
Incumbent Senator is the representative of the entire Khmer citizen, by not only the representative of his/her regions.

**Article 3:**
Senator has 6 (six) years term and the term is terminated when new Senator takes office.

## Chapter II
## Parliamentary Immunity

**Article 4:**
Senator shall have parliamentary immunity. The parliamentary immunity is divided into two parts:

- Absolute immunity is to ensure the expression of opinion or ideas within adoptions of Senator within the framework of his/her duty performance.
- Relative immunity is to ensure that Senator is refrain from accusation, arrest or detention.

**Article 5:**
Senator shall not use his/her parliamentary immunity to violate the dignity of another individual, good social custom and tradition, public order and national security.

**Article 6:**
Senator shall abide by the Internal Regulations of the Senate of the Kingdom of Cambodia.

**Article 7:**
Senator who commits any criminal offence in flagrant delicto, may be accused, or detained in accordance with laws and procedures after his/her parliamentary immunity is lifted.

**Article 8:**
Any proposal of parliamentary immunity lift of an individual Senator shall be made by the General Prosecutor of the Appeal Court through the Ministry of Justice, enclosed herewith an explanatory statement submitted to the President of Senate.

**Article 9:**
If a proposal of parliamentary immunity lift is received within the period of plenary session of the Senate, the following procedures shall apply:

- Senate may hold a closed-door session in response to the request of the President or at least one-tenth of the Senators or His Majesty the King or the Prime Minister or President of the National Assembly
- The quorum for the session shall be more than two-third of the entire Senators

- The adoption shall be done by a two-third majority of the entire Senators.

**Article 10:**

If a proposal of parliamentary immunity lift is received between the plenary sessions of the Senate, the Permanent Committee of the Senate shall meet and decide in accordance with its Internal Regulation.

**Article 11:**

The decision of the Permanent Committee of the Senate shall be submitted for next plenary session of the Senate in order for a vote of two-third majority of the entire Senators.

**Article 12:**

In case of a Senator commits a criminal offence in flagrant delicto, a competent authority may accuse, arrest, or detain him/her and it shall immediately report to the Senate or the Permanent Committee of the Senate within between urgent plenary session of the Senate for approval.

**Article 13:**

In all above cases, detention and accusation of any Senator, in pursuant to the preceding articles, shall be suspended by two-third majority vote of the entire Senators.

**Article 14:**

Senator, who his/her parliamentary immunity is lifted and is accused by the court, shall generally has the same rights and privileges as other Senators.

Senator who is under temporary arrest or detention shall lose his/her rights to attend the plenary session of the Senate and sessions of the commissions, but he/she has rights to receive remunerations, except meeting allowances, mission and gasoline fee.

Senator who is convicted by court shall lose all his/her rights and privileges and membership as Senator.

**Article 15:**
Any Senator, who is granted a pardon by His Majesty the King, shall reinstate his/her parliamentary immunity and privileges.

**Article 16:**
Any Senator, who is acquired of the charges against him/her, shall automatically reinstate his/her parliamentary immunity and privileges.

## Chapter III
## Incompatibility

**Article 17:**
The mandate of Senator is incompatible with active performance of public function, membership in the National Assembly, and function as a member of any other institution in which stipulated in the Constitution and the existing laws.

## Chapter IV
## Remuneration, Status and Privilege

**Article 18:**
The Senate has an autonomous budget to ensure its functioning.

Senator shall receive his/her remuneration.

A Senator shall enjoy the same rank and privilege as same as the highest rank of officers of the Kingdom of Cambodia.

Every Senator shall be covered by social insurance during his/her mandate.

If any Senator passes away during his/her mandate, the Permanent Committee shall be responsible for organizing his/her funeral and shall pay the remuneration and other allowances to his/her family for a year after the date of his/her death.

The Permanent Committee of the Senate shall arrange remuneration, social insurance coverage, financial assistance for medical care, pension, mission allowances and work conditions of each Senator.

**Article 19:**
Senator shall receive a pension.

The pension of Senator may only be cashed out at the Secretariat General of Senate.

The pension can be cashed at only a single place.

The Permanent Committee of the Senate shall allow a Senator to retire upon his/her request.

**Article 20:**
Ex-Senator shall receive a pension at:

a. He/she has been a member of the Senate, a member of the National Assembly since 1993, then performs as a Senator since 1998.
b. 60 years of age or older
c. Do not receive pension from any other public institution.

**Article 21-New:**
The pension of ex-individual Senator shall be based on remuneration and all other allowances of the year in which he/she receives in consistence with his/her rank and position equals to 100% (one hundred).

The monthly pension shall be calculated based on the duration of his/her duty performance are as followed:

| | | |
|---|---|---|
| - | 1 to 3 years of services | 0.5% |
| - | 3 to less than 6 years of services | 1% |
| - | 6 to less than 11 years of services | 2% |
| - | 11 to less than 16 years of services | 3% |
| - | More than 16 years of services | 4% |

Ex-Senator receives his/her monthly pension until his/her death.

The retired Senator who is re-appointed or re-elected as Senator or Member of the National Assembly or Member of the Constitutional Council, shall not be allowed to

receive his/her pension. The individual shall receive his/her entire net pension as Member of Parliament or Member of the Constitutional Council as regular, and at the end of his/her mandate, he/she receives the new pension which is adjusted based on his/her seniority.

**Article 22:**
Ex-Senator, who is not re-elected and turning to 60 years of age, his/her entire pension may be paid off within a single year.

**Article 23:**
Senator shall have personal assistants, in order to assist his/her work, with the condition as contract staffs determined by the Permanent Committee. Their salary shall be paid by the budget of the Senate.

The Secretariat General of the Senate shall facilitate the work of the Senator in pursuance with the Internal Regulation of the Senate.

**Article 24:**
Incumbent Senator shall be provided with the following:

- Immunity card
- A Senate logo attached to a shirt
- A spiritual logo of the Senate
- A Senate vehicle number plate
- A personal diplomatic passport for himself/herself, for his/her spouse and children under 18 years of age
- A Senator uniform
- Decoration (twice per term)

- Financial assistance, from the Senate budget, for treatment in a public hospital in the Kingdom of Cambodia.

**Article 25:**
A civil servant or member of the armed force, who is elected as a Senator, shall automatically be promoted and his/her seniority shall be maintained for his/her pension.

**Article 26:**
Incumbent Senator may use the title of His/her Excellency ex-Senator after they cease to be a Senator.

## Chapter V
## Financial Provision

**Article 27:**
Any provision is contrary to this law shall be nullified.